ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.......សហវ.......

ថ្ងៃ ......... ខែ ....... ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ....... ឆ្នាំ ២០២១

**ជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីសំណើសុំផ្ទេរឥណទានថវិការបស់អង្គភាពមួយចំនួនចូលអង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា។

**យោង៖** -លិខិតលេខ ៤៥៧១ អយក.ហវ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០២០ របស់ក្រសួងអប់រំ យុវជន និងកីឡា

-លិខិតលេខ ៧០៦ សជណ.អវ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ជ្រាបថា បន្ទាប់ពីបានពិនិត្យលើសំណើសុំរបស់ក្រសួងអប់រំ យុវជន និងកីឡារួចមក, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចផ្តល់ការឯកភាពជាគោលការណ៍ ដូចខាងក្រោម៖

**ក) មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ, សាលាគរុកោសល្យ និងវិក្រឹត្យការខេត្ត**

- អនុញ្ញាតឱ្យផ្ទេរឥណទានថវិការបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ, សាលាគរុកោសល្យនិងវិក្រឹត្យការខេត្ត មកនៅក្រោមការគ្រប់គ្រងរបស់អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ។
- អង្គភាពទាំងនេះត្រូវបន្តអនុវត្តតាមបទដ្ឋានគតិយុត្ត និងគោលការណ៍ដែលមានជាធរមាន ផ្អែកតាមស្មារតីនៃ ១)-លិខិតលេខ ៥៥៥៩ សហវ.អថ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២០ ស្តីពីគោលការណ៍ដោះស្រាយបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ និងឆ្នាំបន្តបន្ទាប់នៅក្រសួងអប់រំ យុវជន និងកីឡា, **ត្រង់ចំណុចទី ៣** ដែលបានអនុញ្ញាតឱ្យមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹត្យការខេត្ត ប្រើប្រាស់អនុគណនីចំនួន ៤ (៦០០២៨, ៦០០៥៨, ៦១០៥៨ និង ៦១១០៨) សម្រាប់អនុវត្តថវិកាក្នុងក្របខណ្ឌដំណើរការគ្រឹះស្ថានសាមី ដោយយកលំនាំតាមការអនុវត្តថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ និង ២)-លិខិតលេខ ៨០១៥ សហវ.អថ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលគោលការណ៍ចំណាយមួយចំនួន សម្រាប់អនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ សាលាគរុកោសល្យនិងវិក្រឹត្យការខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចាប់ពីឆ្នាំ ២០១៩ តទៅ។

**ខ) អគ្គនាយកដ្ឋានយុវជន, នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ, នាយកដ្ឋានព័ត៌មានកិច្ចការអាស៊ាន, នាយកដ្ឋានកិច្ចការប្រឡង និងវិទ្យាស្ថានជាតិអប់រំពិសេស**

អនុញ្ញាតឱ្យផ្ទេរឥណទានថវិការបស់អគ្គនាយកដ្ឋានយុវជន, នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ, នាយកដ្ឋានព័ត៌មានកិច្ចការអាស៊ាន នាយកដ្ឋានកិច្ចការប្រឡង និងវិទ្យាស្ថានជាតិអប់រំពិសេស មកនៅក្រោមការគ្រប់គ្រងរបស់

អង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុ សម្រាប់ការអនុវត្តតែនៅក្នុងឆ្នាំ ២០២១ ប៉ុណ្ណោះ ដោយក្រសួងអប់រំ យុវជន និងកីឡាត្រូវចាត់វិធានការដូចខាងក្រោម÷

១)- កែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធអង្គភាពថវិកា ដោយកំណត់អង្គភាពថវិកានៅកម្រិតអគ្គនាយកដ្ឋាន ឬកម្រិតប្រហាក់ប្រហែល ឱ្យស្របតាមគោលការណ៍ណែនាំស្ដីពីការបង្កើតអង្គភាពថវិកា។ ការងារនេះ ត្រូវរៀបចំឱ្យបានរួចរាល់នៅមុនពេលរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤។

២)- ពិនិត្យធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការអនុវត្តថវិកាដល់អង្គភាពមួយចំនួនដែលមានបទពិសោធន៍គ្រប់គ្រាន់ឱ្យទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ។

៣)- ពង្រឹងសមត្ថភាពយន្តការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីឱ្យយន្តការនេះ បំពេញតួនាទីប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្របតាមទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្ដល់កិច្ចសហការផ្នែកបច្ចេកទេស ក្នុងការចូលរួមបណ្ដុះបណ្ដាលជូនដល់មន្ត្រីជំនាញឱ្យបានយល់ដឹងអំពីនីតិវិធីហិរញ្ញវត្ថុ និងក្របខណ្ឌគតិយុត្តពាក់ព័ន្ធជាធរមាន។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**